# ព្រឹត្តិប័ត្រក្រុមប្រឹក្សាអាជ្ញាកណ្ដាល

អនុស្សារណៈនៃការយោគយល់គ្នា ស្ដីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងការកាត់សេចក្ដី ដោយអាជ្ញាកណ្ដាលចងកាតព្វកិច្ច

មិថុនា ២០១១


## ការដោះស្រាយវិវាទការងារដែលគ្របដណ្ដប់ដោយអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងខែមិថុនាឆ្នាំ ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលសំណុំរឿងវិវាទការងារចំនួន ១៧ ដែលចំនួននេះជាកំណត់ត្រាខ្ពស់បំផុតចាប់តាំងពីការបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងឆ្នាំ២០០៣ ហើយដែលនៅក្នុងនោះមានសំណុំរឿង៦ គ្របដណ្ដប់ដោយ MoU ។

ជាសរុប ចាប់ពីខែមករាដល់ ខែមិថុនា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលសំណុំរឿងវិវាទការងារចំនួន ៧៨ ដែលនៅក្នុងនោះមានសំណុំរឿង ៤០ (៥១%) គ្របដណ្ដប់ដោយ MoU ។ សំណុំរឿងចំនួន ១៧ (២២%) ត្រូវបានធ្វើការផ្សះផ្សាដោយជោគជ័យដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល (ទាំងនៅមុន ក្នុងពេល និងក្រោយពេលសវនាការ) ហើយសំណុំរឿងចំនួន ៤៦ (៥៩%) ត្រូវបានដោះស្រាយដោយសេចក្ដីបង្គាប់អាជ្ញាកណ្ដាល និងសំណុំរឿងចំនួន ១៥ (១៩%) គឺកំពុងនៅក្នុងដំណើរការដោះស្រាយ ។ តារាងខាងក្រោមបង្ហាញពីចំនួនសំណុំរឿងសរុបដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលបាន ដោយបែងចែកជាសំណុំរឿងគ្របដណ្ដប់ដោយ MoU និងសំណុំរឿងមិនគ្របដណ្ដប់ដោយ MoU និងលទ្ធផលជារួមអំពីការដោះស្រាយវិវាទការងារ ។



## ការសង្កេតលើការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលកាត់សេចក្តីដោយអាជ្ញាកណ្តាលជាប់កាតព្វកិច្ច

នៅក្នុងខែមិថុនា ឆ្នាំ ២០១១ មានសំណុំរឿង MoU ចំនួន ៦ បានចុះបញ្ជី ដែលនៅក្នុងនោះ មានសវនាការលើសំណុំរឿងចំនួន ៣ ក្នុងរយៈពេលធ្វើរបាយការណ៍នេះ។ ភាគីនៅក្នុងសំណុំរឿងមួយ ក្នុងចំណោមសំណុំរឿងទាំងបីនេះ បានឈានដល់កិច្ចព្រមព្រៀងនៅក្នុងសវនាការ ។ ក្នុងចំណោមដំណើរការអាជ្ញាកណ្តាលទាំងអស់ យើងបានសង្កេតឃើញថាៈ

១. ការវិវត្តន៏ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈ

- នៅក្នុងសំណុំរឿង ៣ ភាគីបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងដាច់ដោយឡែក បញ្ជាក់ពីការជ្រើសរើសយកអាជ្ញាកណ្តាល ជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ ។
- នៅក្នុងសំណុំរឿង ៣ ភាគីបានយល់ដឹងអំពីបទប្បញ្ញត្តិរបស់ MoU ជាពិសេសទាក់ទងនឹង អាជ្ញាកណ្តាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ ។
- នៅក្នុងសំណុំរឿង ៣ មិនមានសកម្មភាពឧស្សាហកម្ម (កូដកម្ម ឬឡុកអៅ) ពាក់ព័ន្ធក្នុងអំឡុងពេលការដោះស្រាយវិវាទ ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។
- នៅក្នុងសំណុំរឿង ៣ ភាគីនិយោជករៀបចំបានល្អក្នុងការបង្ហាញឯកសារចាំបាច់ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា ។
- នៅក្នុងសំណុំរឿង ១ ភាគីកម្មករនិយោជិតរៀបចំបានល្អក្នុងការបង្ហាញឯកសារចាំបាច់សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ។
- នៅក្នុងសំណុំរឿង ៣ ភាគីបានបង្ហាញអង្គហេតុ និងភស្តុតាងយ៉ាងគ្រប់គ្រាន់ ដើម្បីគាំទ្រសំណុំរឿងរបស់ខ្លួន ។
- នៅក្នុងសំណុំរឿង ២ ភាគីបង្ហាញឆន្ទៈរបស់ខ្លួន ដើម្បីដោះស្រាយវិវាទតាមរយៈកិច្ចព្រមព្រៀង ។ នៅក្នុងសំណុំរឿង ១ ការយល់ដឹងបានល្អរបស់ភាគីទៅលើបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធជួយឱ្យពួកគេឈានទៅដល់កិច្ចព្រមព្រៀងមួយ ។
- នៅក្នុងសំណុំរឿង ៣ ភាគីមានវត្តមានទាំងអស់នៅក្នុងសវនាការ ។

២. បញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

- នៅក្នុងសំណុំរឿង ២ កម្មករនិយោជិតមិនបានរៀបចំឱ្យបានល្អ ហើយខកខានបង្ហាញឯកសារចាំបាច់ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។
- នៅក្នុងសំណុំរឿង ១ ភាគីមិនបានសហការជាមួយនឹងគ្នា នៅក្នុងការដោះស្រាយវិវាទដោយកិច្ចព្រមព្រៀង ។ ភាគីកម្មករនិយោជិតបានដកចំណុចវិវាទ ដែលពួកគេដឹងថាជាវិវាទអំពីផលប្រយោជន៏ ។

---

យើងគោរពភាពឯកជនរបស់លោកអ្នក ហើយនៅក្នុងករណីណាក៏ដោយ យើងនឹងមិនបញ្ចេញព័ត៌មានទំនាក់ទំនងលម្អិតរបស់លោកអ្នក ទៅបុគ្គលណាម្នាក់ រឺអង្គការណាមួយឡើយ ។
ដើម្បីទទួល រឺ ឈប់ទទួល ព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ dvandeth@arbitrationcouncil.org

ផ្ទះលេខ៧២ ផ្លូវ៥៩២ កែង ផ្លូវលេខ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក
ទូរសព្ទ: ៨៥៥ ២៣ ៨៨១ ៨១៤
ទូរសារ: ៨៥៥ ២៣ ៨៨១ ៩១៨
អ៊ីម៉ែល info@arbitrationcouncil.org
វែបសាយ www.arbitrationcouncil.org